# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ៧៧០ MOC / SM 2008

## ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានមន្ទីរពិសោធន៍

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៩អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ : នាយកដ្ឋានមន្ទីរពិសោធន៍** ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មានតួនាទី និងភារកិច្ចដូចតទៅ ៖-

- រៀបចំឱ្យមានប្រព័ន្ធធានាគុណភាពសម្រាប់មន្ទីរពិសោធន៍ និងអនុវត្តការងារតាមប្រព័ន្ធនេះ ឱ្យមានប្រសិទ្ធភាព
- កសាងកម្មវិធីត្រួតពិនិត្យគុណភាពសម្រាប់ការធ្វើតេស្ត (Quality Control Programs for Testing) និងឯកសារស្តីពីប្រព័ន្ធគុណភាព ជាអាទិ៍គោលនយោបាយ និងវិធានការងារវិធីសាស្ត្រកំណត់ត្រា ទម្រង់ឯកសារ និងស្តង់ដារសម្រាប់អនុវត្តការងារមន្ទីរពិសោធន៍
- ទទួលធ្វើតេស្ត និងយកគំរូសម្រាប់ធ្វើតេស្តកំណត់ចរិតលក្ខណៈរូប គីមី និងមីក្រូជីវសាស្ត្រលើផលិតផលម្ហូបអាហារ និងផលិតផលមិនមែនម្ហូបអាហារ ទៅតាមវិសាលភាពដែលបានតាមការកំណត់ជាក់លាក់
- អនុវត្តកម្មវិធីត្រួតពិនិត្យគុណភាពខាងក្រៅ(External Quality Control Progams) ដោយសហការជាមួយមន្ទីរពិសោធន៍ដទៃទៀត ។ ចូលរួមក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ប្រសិទ្ធភាពធ្វើតេស្តរបស់មន្ទីរពិសោធន៍



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨

ជាមួយអន្តរមន្ទីរពិសោធន៍ ក្នុងកម្មវិធីធ្វើពិសោធន៍ដែលមានប្រសិទ្ធភាព (Proficiency Testing Schemes) ដែលរៀបចំដោយស្ថាប័នទទួលស្គាល់អន្តរជាតិ

- រៀបចំកម្មវិធី និងនីតិវិធីយកគំរូផលិតផលម្ហូបអាហារ និងមិនមែនម្ហូបអាហារសម្រាប់អនុវត្តនៅតាមសាខាកាំកុងត្រូលប្រចាំខេត្ត ក្រុង តាមដានការអនុវត្តការងារនេះ ទទួលវិភាគ វាយតម្លៃភាពសមស្របរបស់ផលិតផល រក្សា និងគ្រប់គ្រងទិន្នន័យវិភាគឱ្យបានត្រឹមត្រូវ
- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសំណូមពរសម្រាប់អភិវឌ្ឍសមត្ថភាពធ្វើតេស្តរបស់មន្ទីរពិសោធន៍ស្រមតាមស្ថានភាពជាក់ស្តែង និងការតម្រូវចាំបាច់
- រៀបចំឱ្យមានការធ្វើសវនកម្មផ្ទៃក្នុង លើការអនុវត្តការងាររបស់មន្ទីរពិសោធន៍ តាមពេលវេលាកំណត់ជាក់លាក់
- កំណត់វិសាលភាពតេស្តសម្រាប់ការស្នើសុំវាយតម្លៃលើសមត្ថភាព ពីស្ថាប័នទទួលស្គាល់អន្តរជាតិរៀបចំ និងចាត់ចែងការងារនេះឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌតម្រូវ ដើម្បីទទួលបានការទទួលស្គាល់ផ្លូវការលើសមត្ថភាពរបស់មន្ទីរពិសោធន៍
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ២** : នាយកដ្ឋានមន្ទីរពិសោធន៍ មានការិយាល័យចំណុះចំនួន ៤ ៖-

១-ការិយាល័យគ្រប់គ្រងកិច្ចធានាគុណភាពមន្ទីរពិសោធន៍

២-ការិយាល័យវិភាគមីក្រូជីវសាស្ត្រម្ហូបអាហារ

៣-ការិយាល័យវិភាគរូបសាស្ត្រ និងគីមីសាស្ត្រម្ហូបអាហារ

៤-ការិយាល័យវិភាគប្រេងឥន្ធនៈ និងផលិតផលមិនមែនម្ហូបអាហារ

ការិយាល័យនិមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន តាមការចាំបាច់ ។

**ប្រការ៣ : ការិយាល័យគ្រប់គ្រងកិច្ចធានាគុណភាពមន្ទីរពិសោធន៍** ទទួលបន្ទុក:

- រៀបចំ និងធានាការអនុវត្តប្រព័ន្ធធានាគុណភាពក្នុងមន្ទីរពិសោធន៍
- កសាងនីតិវិធី និងស្តង់ដារសម្រាប់ការយកគំរូ និងវិភាគផលិតផល
- យកគំរូ ទទួល និងគ្រប់គ្រងគំរូ សម្រាប់ធ្វើតេស្តតាមមុខសញ្ញាជាក់លាក់
- គ្រប់គ្រង ប្រតិករគីមី សម្ភារៈ និងបរិក្ខារមន្ទីរពិសោធន៍ឱ្យបានត្រឹមត្រូវ
- រៀបចំកម្មវិធីបណ្តុះបណ្តាលមន្ត្រីមន្ទីរពិសោធន៍
- រៀបចំយុទ្ធសាស្ត្រ ផែនការគម្រោង និងសំណូមពរសម្រាប់អភិវឌ្ឍន៍សមត្ថភាពធ្វើតេស្តរបស់មន្ទីរពិសោធន៍ស្របតាមស្ថានភាពជាក់ស្តែង និងការតម្រូវចាំបាច់
- ធ្វើរបាយកាណ៍ និងគ្រប់គ្រងថវិកាចំណូល និងចំណាយរបស់នាយកដ្ឋានមន្ទីរពិសោធន៍សម្រាប់បង់ចូលថវិកា
- កសាង និងអនុវត្តកម្មវិធីសវនកម្មផ្ទៃក្នុង នៅក្នុងមន្ទីរពិសោធន៍
- ធ្វើរបាយការណ៍បច្ចេកទេសដែលពាក់ព័ន្ធសមត្ថភាព និងការអនុវត្តរបស់មន្ទីរពិសោធន៍
- គ្រប់គ្រងឯកសារបច្ចេកទេស និងទិន្នន័យតេស្តរបស់មន្ទីរពិសោធន៍
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៤ : ការិយាល័យវិភាគមីក្រូជីវសាស្ត្រម្ហូបអាហារ** ទទួលបន្ទុក :

- ទទួលគំរូសម្រាប់វិភាគមីក្រូជីវសាស្ត្រ ម្ហូបអាហារ ។ ថែរក្សា ទុកដាក់ និងរៀបចំគំរូឱ្យបានត្រឹមត្រូវតាមលក្ខខ័ណ្ឌបច្ចេកទេស
- វិភាគមីក្រូជីវសាស្ត្រ ម្ហូបអាហារដោយអនុវត្តឱ្យបានត្រឹមត្រូវទាំងស្រុងតាមនីតិវិធីដែលមានសុពលភាព



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨

- ប្រើប្រាស់ ថែទាំ និងធានាភាពត្រឹមត្រូវរបស់ឧបករណ៍វិភាគ
- ធ្វើរបាយការណ៍វិភាគ និងគ្រប់គ្រងទិន្នន័យវិភាគមីក្រូជីវសាស្ត្រម្ហូបអាហារ
- អនុវត្តកម្មវិធីធានាគុណភាពការធ្វើតេស្ត និងចូលរួមក្នុងកម្មវិធីបង្កើនប្រសិទ្ធភាពការធ្វើតេស្ត ជាមួយអន្តរមន្ទីរពិសោធន៍
- គ្រប់គ្រងប្រតិករមីក្រូជីវសាស្ត្រ សម្ភារៈ និងបរិក្ខារមន្ទីរពិសោធន៍
- ធានាសុវត្ថិភាពការងារ និងភាពស្អាតរបស់មន្ទីរពិសោធន៍
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**<u>ប្រការ៥</u> : ការិយាល័យវិភាគរូបសាស្ត្រ និងគីមីសាស្ត្រម្ហូបអាហារ** ទទួលបន្ទុក :

- ទទួលគំរូសម្រាប់វិភាគរូបសាស្ត្រ និងគីមីសាស្ត្រម្ហូបអាហារ ។ ថែរក្សា ទុកដាក់ និងរៀបចំគំរូឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌបច្ចេកទេស
- វិភាគរូប គីមី ម្ហូបអាហារដោយអនុវត្តឱ្យបានត្រឹមត្រូវទាំងស្រុងតាមនីតិវិធីដែលមានសុពលភាព
- ប្រើប្រាស់ ថែទាំ និងធានាភាពត្រឹមត្រូវរបស់ឧបករណ៍វិភាគ
- ធ្វើរបាយការណ៍វិភាគ និងគ្រប់គ្រងទិន្នន័យវិភាគរូបសាស្ត្រ និងគីមីសាស្ត្រម្ហូបអាហារ
- អនុវត្តកម្មវិធីធានាគុណភាពការធ្វើតេស្ត និងចូលរួមក្នុងកម្មវិធីបង្កើនប្រសិទ្ធភាពការធ្វើតេស្ត ជាមួយអន្តរមន្ទីរពិសោធន៍
- គ្រប់គ្រងប្រតិករប្រតិករគីមី សម្ភារៈ និងបរិក្ខារមន្ទីរពិសោធន៍
- ធានាសុវត្ថិភាពការងារ និងភាពស្អាតរបស់មន្ទីរពិសោធន៍
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**<u>ប្រការ៦</u> : ការិយាល័យវិភាគប្រេងឥន្ធនៈ និងផលិតផលមិនមែនម្ហូបអាហារ** ទទួលបន្ទុកៈ

- យកគំរូ និងទទួលគំរូសម្រាប់វិភាគប្រេងឥន្ធនៈ និងផលិតផលមិនមែនម្ហូបអាហារ ។ ថែរក្សា ទុកដាក់ និងរៀបចំគំរូឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌបច្ចេកទេស
- វិភាគកំណត់ចរិតលក្ខណៈរបស់ផលិតផល ដោយអនុវត្តទាំងស្រុងតាមនីតិវិធី
- ប្រើប្រាស់ ថែទាំ និងធានាភាពត្រឹមត្រូវរបស់ឧបករណ៍វិភាគ
- ធ្វើរបាយការណ៍វិភាគ និងគ្រប់គ្រងទិន្នន័យវិភាគផលិតផល
- គ្រប់គ្រងប្រតិករប្រតិករគីមី សម្ភារៈ និងបរិក្ខារមន្ទីរពិសោធន៍
- ធានាសុវត្ថិភាពការងារ និងភាពស្អាតរបស់មន្ទីរពិសោធន៍
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**<u>ប្រការ៧</u>** : នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> :**

-ដូចប្រការ៧

-ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨